**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១៣៧ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៥ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ពង្រឹងសន្តិសុខ សុវត្ថិភាព និងផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ
- ធានានូវការសម្របសម្រួល និងការធ្វើដំណើរដល់ភ្ញៀវទេសចរ
- ធានាប្រសិទ្ធិភាព ការគ្រប់គ្រងការងារ និងការទទួលខុសត្រូវរបស់នាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ។

ឡូត៍លេខ ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ** ចំណុះអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ និងជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារគ្រប់គ្រងសន្តិសុខ និងសុវត្ថិភាពទេសចរ។

**នាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងសន្តិសុខ និងសុវត្ថិភាពទេសចរ
- រៀបចំផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងវិធានការចាំបាច់នានា ក្នុងការពង្រឹងសន្តិសុខ និងសុវត្ថិភាពទេសចរ
- ផ្សព្វផ្សាយ ណែនាំ និងជំរុញឱ្យអាជីវកម្មទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសេវាផ្សេងទៀតបម្រើឱ្យវិស័យទេសចរណ៍ ដើម្បីបង្កើនការការពារសន្តិសុខ និងសុវត្ថិភាពទេសចរ
- ជំរុញ និងត្រួតពិនិត្យប្រព័ន្ធសន្តិសុខ សុវត្ថិភាព និងសម្បទាទេសចរណ៍នៃមូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍
- សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសុខាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការនៅថ្នាក់ក្រោមជាតិ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងវិស័យឯកជនលើកិច្ចការរក្សាសន្តិសុខ និងសុវត្ថិភាពទេសចរ
- សហការជាមួយស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ដើម្បីបង្កើត ពង្រឹង រៀបចំប្រព័ន្ធសង្គ្រោះទេសចរបឋម និងបន្ទាន់ ព្រមទាំងប្រព័ន្ធសុវត្ថិភាពទេសចរផ្សេងៗទៀត
- សហការជាមួយសមត្ថកិច្ចនគរបាលទេសចរណ៍លើការងារពង្រឹងសន្តិសុខនិងសុវត្ថិភាពទេសចរ និងជំរុញឱ្យមានសន្តិសុខស្ម័គ្រចិត្តឯកជននៅតាមតំបន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍នានា
- ជាលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំលើកិច្ចការរក្សាសន្តិសុខ និងសុវត្ថិភាពទេសចរ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ។

នាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ មានការិយាល័យចំណុះចំនួន **០៤(បួន)** ដូចខាងក្រោម៖

១-ការិយាល័យសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរ

២-ការិយាល័យព័ត៌មាន និងផ្សព្វផ្សាយ

៣-ការិយាល័យពង្រឹងសុវត្ថិភាពទេសចរណ៍

៤-ការិយាល័យសម្របសម្រួល និងអន្តរាគមន៍។

ការិយាល័យនីមួយៗដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរ** មានតួនាទី និងភារកិច្ច៖

- សហការចូលរួមតាមដានរាល់សកម្មភាពគ្រប់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេសក្នុងការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តរបស់គណៈកម្មការអន្តរក្រសួង
- សហការចូលរួមចុះធ្វើការងារនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេសជារៀងរាល់ខែ ដើម្បីធ្វើការបូកសរុបរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងក្នុងកិច្ចប្រជុំពេញអង្គ
- សហការជាមួយនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដើម្បីរៀបចំបណ្តុះបណ្តាលមុខជំនាញបដិសណ្ឋារកិច្ច និងសេវាកម្មភ្ញៀវទេសចរជូនដល់ប្រតិបត្តិករទេសចរណ៍ និងសមត្ថកិច្ចតាមច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីអនុវត្តស្តង់ដាបដិសណ្ឋារកិច្ចល្អ សម្រាប់ការប្រឡងប្រណាំងតាមច្រកទ្វារព្រំដែនអន្តជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស។

**២-ការិយាល័យពត៌មាន និងផ្សព្វផ្សាយ** មានតួនាទី និងភារកិច្ច៖

- រៀបចំផែនការយុទ្ធសាស្ត្រលិខិតបទដ្ឋានគតិយុត្តនានា និងសកម្មភាពអនុវត្តការងារ អប់រំ ផ្សព្វផ្សាយសន្តិសុខ និងសុវត្ថិភាពទេសចរ
- សហការគ្រប់គ្រងពត៌មាន អប់រំ និងផ្សព្វផ្សាយសន្តិសុខ និងសុវត្ថិភាពទេសចរ
- សហការរៀបចំកម្មវិធីផ្សព្វផ្សាយ និងការអប់រំយល់ដឹងជាសាធារណៈអំពីសន្តិសុខ និងសុវត្ថិភាពទេសចរ
- សហការអប់រំ ផ្សព្វផ្សាយ ណែនាំ និងជំរុញឱ្យម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍បង្កើនការការពារសន្តិសុខ និងសុវត្ថិភាពទេសចរ
- សហការផ្សព្វផ្សាយ និងជូនដំណឹងអំពីគ្រោះធម្មជាតិផ្សេងៗដែលអាចកើតមានឡើងដល់ភ្ញៀវទេសចរ។

**៣-ការិយាល័យពង្រឹងសុវត្ថិភាពទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្ត និងវិធានការចាំបាច់នានាក្នុងការពង្រឹង និងជំរុញការងារសន្តិសុខ និងសុវត្ថិភាពទេសចរឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព
- រៀបចំផ្តល់បណ្ណសរសើរ លិខិតសរសើរដល់ម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ដែលមានស្នាដៃល្អរួមចំណែកក្នុងការការពារសន្តិសុខ និងសុវត្ថិភាពទេសចរ
- សហការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពទេសចរណ៍
- សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសុខាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ អង្គភាពនៅថ្នាក់ក្រោមជាតិ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ ក្រុមហ៊ុនធានារ៉ាប់រងនិងវិស័យឯកជនរៀបចំវិធានការ និងយន្តការចាំបាច់ទាក់ទងការរក្សាសន្តិសុខនិងសុវត្ថិភាពជូនទេសចរ
- សហការជាមួយស្ថាប័នអាជ្ញាធរពាក់ព័ន្ធដើម្បីបង្កើតនិងពង្រឹងប្រព័ន្ធសង្គ្រោះទេសចរបឋម និងបន្ទាន់ព្រមទាំងប្រព័ន្ធសុវត្ថិភាពទេសចរណ៍ផ្សេងៗទៀត
- សហការរៀបចំប្រព័ន្ធស្តង់ដាសុវត្ថិភាពទេសចរសម្រាប់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍
- សហការត្រួតពិនិត្យ និងពង្រឹងការអនុវត្តការងារសន្តិសុខ និងសុវត្ថិភាពទេសចរនៅតាមរាជធានី ខេត្ត
- សហការតាមដាន និងជំរុញឱ្យម្ចាស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍បង្កើនការការពារសុវត្ថិភាពជូនភ្ញៀវទេសចរ។

**៤.ការិយាល័យសម្របសម្រួល និងអន្តរាគមន៍** មានតួនាទី និងភារកិច្ចៈ

- សិក្សា និងសហការរៀបចំផែនការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនធានារ៉ាប់រង និងវិស័យឯកជនលើការផ្តល់ជាសំណងផ្សេងៗ ដល់ភ្ញៀវទេសចរដែលបានទិញបណ្ណធានារ៉ាប់រង ដែលជួបគ្រោះថ្នាក់អំឡុងពេលធ្វើដំណើរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា
- ជំរុញមន្ទីរទេសចរណ៍រាជធានី ខេត្ត និងផ្នែកឯកជននៃវិស័យទេសចរណ៍ធ្វើរបាយការណ៍អំពីបញ្ហាសន្តិសុខ និងសុវត្ថិភាពទេសចរជាប្រចាំ
- សហការជាមួយសមត្ថកិច្ចនគរបាលទេសចរណ៍លើការងារពង្រឹងសន្តិសុខ សុវត្ថិភាពទេសចរ និងជំរុញឱ្យមានសន្តិសុខស្ម័គ្រចិត្តឯកជននៅតាមតំបន់គោលដៅទេសចរណ៍ និងរមណីយដ្ឋានទេសចរណ៍នានា
- សហការជាមួយស្ថានទូត អគ្គទូតក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងផ្នែកឯកជន ដើម្បីជួយសម្រួល និងអន្តរាគមន៍ឱ្យបានឆាប់រហ័សនៅពេលដែលភ្ញៀវទេសចរជួបគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យនាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ មានតួនាទី និងភារកិច្ចៈ

- រៀបចំគម្រោងផែនការសកម្មភាពការងារប្រចាំឆ្នាំ
- រៀបចំគម្រោងថវិកាចំណាយប្រចាំឆ្នាំ និងចំណាយផ្សេងៗ
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ